ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
លេខ : ២០៤៧ ប្រក

រាជធានីភ្នំពេញ.ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០

# ប្រកាសអន្តរក្រសួង
# មហាផ្ទៃ - សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
# ស្ដីពី
# ការកំណត់ថ្លៃអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញ អនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ ស្ដីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- បានឃើញ អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជារាជរដ្ឋាភិបាលលេខ ០៤ បប ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ២០១៦ ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងលិខិតលេខ ១៦៨០ សជណ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ។

## **សម្រេច**

**ប្រការ ១ :** ត្រូវបានកំណត់ថ្លៃអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដែលផ្តល់ជូនប្រជាពលរដ្ឋ ក្នុងមួយសន្លឹកតម្លៃ ១០.០០០រៀល (ដប់ពាន់រៀល) ។

**ប្រការ ២ :** ប្រាក់ដែលប្រមូលបានពីអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរត្រូវដក ២.០០០រៀល (ពីរពាន់រៀល) ក្នុងមួយសន្លឹក សម្រាប់ :

- ឧបត្ថម្ភដល់កងកម្លាំងប្រតិបត្តិការ ១.៥០០រៀល (មួយពាន់ប្រាំរយរៀល)
- សេវាថែទាំឧបករណ៍ សំភារៈបច្ចេកទេស ៥០០រៀល (ប្រាំរយរៀល) ។

**ប្រការ ៣ :** នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃដើម្បីចុះណែនាំអនុវត្តការប្រមូលអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

**ប្រការ ៤ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ នៃក្រសួងមហាផ្ទៃ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធមានភារកិច្ចអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

គាត ឈន់

**ចម្លងជូន :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
  ដើម្បីជូនជ្រាប
- ដូចប្រការ ៥
  ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ